ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ០៧ លេខ ០១

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

# សកម្មភាព ការងារ

ECOSOCC



ក ស វ

Work Activities

ប្រចាំខែមករា ឆ្នាំ២០១៤



# មាតិកាអត្ថបទ

## កិច្ចប្រជុំជំនាញបច្ចេកទេស រវាងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ក្រុមប្រឹក្សាអ្នកច្បាប់ និងតំណាងអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល


| ល.រ | ឈ្មោះអត្ថបទ | លេខទំព័រ |
|---|---|---|
| ១- | សេចក្តីព្រាងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ | ១ |
| ២- | ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ២០១៣ | ៣ |
| ៣- | សកម្មភាពដទៃទៀតរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ | ១១ |

# សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨

កាលពីថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ នៅទីស្តីការគណៈរដ្ឋមន្ត្រីមានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព ឯកឧត្តម ឌុយ ផៅ អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម ផៃ សុខខេង សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ **សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨** ដោយមានការអញ្ជើញចូលរួមពីសំណាក់សមាជិកនិងមន្ត្រីនៃក.ស.វ. សមាជិកនិងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី សុខ អាន មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងផែនការ។



ដោយមានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្រសួងផែនការបានសម្របសម្រួលនិងដឹកនាំរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ (ផ.យ.អ.ជ.) ដែលត្រូវបានរៀបចំឡើងដោយផ្អែកលើធាតុចូលពីក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាល ក្នុងអំឡុងពេលនៃកិច្ចប្រជុំអន្តរក្រសួងចំនួនពីរលើក(កម្រិតបច្ចេកទេសនិងកម្រិតនយោបាយ)។ ផែនការនេះ គឺជាប្រធានបទគោលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងវេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា ដែលនឹងរៀបចំឡើងនៅ ថ្ងៃទី៥-៦ ខែមីនា ២០១៤។

សេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះ ត្រូវបានរៀបចំឡើងបន្តពីផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដែលត្រូវបានចប់អាណត្តិកាល នាចុងឆ្នាំ២០១៣ ក្នុងនីតិកាលទី៤ នៃរដ្ឋសភាកន្លងទៅ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិនេះនឹងមានតួនាទីយ៉ាងសំខាន់ក្នុងការអនុវត្តគោលនយោបាយអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។

ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ នេះត្រូវបានរៀបចំឡើង ដើម្បីសម្រេចនូវវត្ថុបំណងសំខាន់បី ទី១-ដើម្បីវាយតម្លៃអំពីលទ្ធផលរួមនិងបញ្ហាប្រឈមចម្បងៗ ដែលបានកើតមានឡើងនៅក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ក្នុងអាណត្តិកាលរបស់ផែនការនេះទាំងមូល ពីឆ្នាំ ២០០៩ ដល់ឆ្នាំ២០១៣ ទី២-ដើម្បីកំណត់នូវបណ្តាវិធានការគោលនយោបាយនានា ដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ សម្រាប់ការអនុវត្តគោលនយោបាយអាទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជាតាមវិស័យ នៅក្នុងដំណាក់កាលនៃអាណត្តិកាលរបស់ផែនការ ដើម្បីស្ថិរភាពកំណើនសេដ្ឋកិច្ច កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា និងទី៣-ដើម្បីដាក់ចេញនូវប្រព័ន្ធមួយ សម្រាប់តាមដាន ត្រួតពិនិត្យនិងវាយតម្លៃប្រចាំឆ្នាំ នូវការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨ របស់ក្រសួង ស្ថាប័ននានា។

ដំណើរការរៀបចំផែនការថ្មីនេះ បានត្រូវចាប់ផ្តើមជាជំហានៗ តាំងពីចុងឆ្នាំ២០១២ មកម្ល៉េះ ដោយក្រសួងផែនការបាន ១-រៀបចំនូវឯកសារទស្សនទានសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ដោយបានធ្វើការពិភាក្សាក្នុងកិច្ចប្រជុំអន្តរក្រសួងទាំងកម្រិតបច្ចេកទេស ទាំងកម្រិតនយោបាយ ព្រមទាំងត្រូវបានពិភាក្សាផ្តល់អនុសាសន៍នៅក្នុងកិច្ចប្រជុំឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិផងដែរ ២-ការពិគ្រោះពិភាក្សាកែសម្រួលសូចនាករស្នូល សម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្ត ផ.យ.អ.ជ. បច្ចុប្បន្នកម្ម និង ៣-ការណែនាំអំពីការរៀបចំធាតុចូល(១)។

អង្គប្រជុំជំនាញបច្ចេកទេសបានពិនិត្យពិភាក្សាលើសេចក្តីព្រាងឯកសារនេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារ ពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងនេះកាន់តែល្អ។

អង្គប្រជុំជំនាញបច្ចេកទេសបានបញ្ចប់ការពិភាក្សាលើសេចក្តីព្រាងនេះទាំងស្រុង។

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុនៃសេចក្តីព្រាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៤-២០១៨។

# ស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំឆ្នាំ២០១៣*



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជាប្រចាំឆ្នាំ២០១៣នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) នៅថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ ដែលដឹកនាំដោយឯកឧត្តម **យឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយមានការអញ្ជើញចូលរួមពីសំណាក់ សមាជិក-សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➢ អត្រាអតិផរណាឆ្នាំ២០១៣ ស្មើនឹង ៣,០% ក្នុងនោះ ក្រុមទំនិញដែលឡើងថ្លៃលើសអត្រាមធ្យម៣,០% នេះ មាន ម្ហូបអាហារ សម្លៀកបំពាក់និងស្បែកជើង សុខាភិបាល ការកម្សាន្តនិងវប្បធម៌ ការសិក្សា និងភោជនីយដ្ឋាន។

តារាងខាងក្រោម បង្ហាញបម្រែបម្រួលសន្ទស្សន៍ថ្លៃតាមក្រុមទំនិញ

| ល.រ. | ក្រុមទំនិញ | អតិផរណាឆ្នាំ២០១៣ | អត្រារួមចំណែក | អតិផរណាឆ្នាំ២០១២ |
|---|---|---|---|---|
| ០ | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ៣,០% | ១០០% | ២,៩% |
| ១ | ម្ហូបអាហារ | ៣,៩% | ៥៦% | ៣,៣% |
| ២ | ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់ | ៣,១% | ១,៧% | ២,០% |
| ៣ | សម្លៀកបំពាក់ និងស្បែកជើង | ៤,៧% | ៤,៩% | ៤,១% |
| ៤ | ផ្ទះសំបែង ទឹក អគ្គិសនី ឧស្ម័ន ... | ០,៧% | ៤% | ២,២% |
| ៥ | គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ៣% | ២,៨% | ៣,៣% |
| ៦ | សុខាភិបាល | ៥,១% | ៨,៧% | -០,៧% |
| ៧ | ការដឹកជញ្ជូន | -០,៦% | -២% | ៣,២% |
| | ក្នុងនោះ ប្រេងសាំង | -០,៨% | -១% | ៥% |
| ៨ | ទូរគមនាគមន៍ | -១,៥% | -០,៦% | -១,៦% |
| ៩ | ការកម្សាន្ត និងវប្បធម៌ | ៤,៨% | ៤,៧% | ០,៦% |
| ១០ | ការសិក្សា | ៥,០% | ២,០% | ២,៤% |
| ១១ | ភោជនីយដ្ឋាន | ៥,៥% | ១១% | ៤,៧% |
| ១២ | ទំនិញ និងសេវាកម្មផ្សេងៗ | -២,៦% | -២,០% | ៤,៦% |

⇨ក្រុមទំនិញដែលមានសន្ទស្សន៍ថ្លៃថយចុះមាន ការដឹកជញ្ជូន ទូរគមនាគមន៍ និងទំនិញនិងសេវាកម្មផ្សេងៗ។

តារាងខាងក្រោមបង្ហាញអតិផរណាប្រចាំខែ ២០១១-២០១៣(ដែលជាការឡើងនៃថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន)។

| | ធៀបនឹង... | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៣ | ខែដូចគ្នាឆ្នាំមុន | ១៨%, | ១,៧% | ១,0% | ១,0% | ២,៨% | ២,៩% | ៤,0% | ៣,៣% | ៣,៩% | ៤,២% | ៤,២% | ៤,៧% | ៣,0% |
| ២០១២ | ខែដូចគ្នាឆ្នាំមុន | ៥,៨% | ៥,៤% | ៥,៤% | ៤,៨% | ២,២% | ១,៨% | ១,៣% | ២,២% | ១,៤% | ១,២% | ១,៦% | ២,៦% | ២,៩% |
| ២០១១ | ខែដូចគ្នាឆ្នាំមុន | ៣,៣% | ៣,៨% | ៣,៨% | ៥,២% | ៦,៥% | ៧,១% | ៧,១% | ៦,៤% | ៦,៧% | ៥,៣% | ៥,៦% | ៤,៩% | ៥,៥% |

⇨ មុខទំនិញដែលមានការឡើងថ្លៃគួរឲ្យកត់សម្គាល់មានសាច់គោស្រស់ ១២% និងបន្លែ ៧,២% ។

➢ **អត្រាប្តូរប្រាក់៖**

⇨ ជារួមអត្រាប្តូរប្រាក់រៀល ធៀបនឹងរូបិយប័ណ្ណបរទេសមានស្ថេរភាព។ នាចុងឆ្នាំ២០១៣ អត្រាប្តូរប្រាក់រៀល ធៀបនឹងរូបិយប័ណ្ណមួយចំនួន មានស្ថានភាពដូចខាងក្រោម៖

- ប្រាក់រៀលស្ថិតនៅថេរ ធៀបនឹងដុល្លារស.រ.អា និងមានអត្រា ៣៩៩៥រ/ដុល្លារ
- ប្រាក់រៀលឡើងថ្លៃ ៦,៩% ធៀបនឹងបាតថៃ និងមានអត្រា ១២២រ/បាត
- ប្រាក់រៀលឡើងថ្លៃ 0,៥% ធៀបនឹងដុងវៀតណាម និងមានអត្រា 0,១៩0រ/ដុង ។

## ២) ស្ថានភាពថវិកាជាតិ

➢ យោងតាមស្ថិតិដែលឆ្លងកាត់រតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០១៣នេះ អនុវត្តបានចំនួន ៨០៦៥ ពាន់លានរៀល ស្មើនឹង ៦៨% នៃច្បាប់ថវិកា ក្នុងនោះចំណូលចរន្ត ៧៧១១ ពាន់លានរៀល ស្មើនឹង ៩១% នៃច្បាប់ថវិកា និងចំណូលមូលធន ៣៤៨ពាន់លានរៀល។

➢ បើធៀបនឹងឆ្នាំ២០១២ ចំណូលថវិកាជាតិកើនឡើង ២% ដែលក្នុងនោះ ចំណូលចរន្តកើនឡើង ៣% និងចំណូលមូលធនថយចុះ ៦% ។

⇨ ការកើនឡើងនៃចំណូលចរន្ត ជាចម្បងបណ្តាលមកពីចំណូលសារពើពន្ធកើនឡើង ៦%។ រីឯចំណូលមិនមែនសារពើពន្ធថយចុះ១៥% ។



| មុខចំណូល | អនុវត្តច្បាប់ថវិកា | %Δធៀបនឹងឆ្នាំ២០១២ |
|---|---|---|
| **ចំណូលសារពើពន្ធ** * | ៩២% | +៦% |
| ✓**ពន្ធ និងអាករគយ** ** | ១០០% | +១០% |
| –ពន្ធគយ (របបនាំចូល) | ៩៧% | +១០% |
| –អាករពិសេសលើរបបនាំចូល | ៩៣% | +៤% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | ១០៦% | +១២% |
| –អាករនាំចេញ | ១២៦% | +១% |
| –អាករបន្ថែមលើគេលសិលា | ៨៩% | ០% |
| ✓**ចំណូលពន្ធដារ** *** | ១០២% | +១៩% |
| –ពន្ធលើប្រាក់បៀវត្ស | ១០៥% | +២៨% |
| – ពន្ធលើប្រាក់ចំណេញ | ៩៧% | +២១% |
| – ពន្ធលើឈ្នួលផ្ទះ–ដី | ១០៥% | +២៤% |
| – អាករលើផលរបរ | ៧៩% | +៨% |
| – អាករលើតម្លៃបន្ថែម | ១០០% | +២២% |
| – អាករពិសេស | ៩៩% | +១៦% |
| – ពន្ធថវិកាខេត្តរាជធានី | ១២១% | +៧% |
| ✓**ចំណូលសារពើពន្ធផ្សេងៗ** * | ១០៩% | +៥% |
| –ចំណូលពីកាស៊ីណូ | ១០៩% | -៣៦% |
| –ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក | ៨០% | -៥២% |
| – កម្រៃការគ្រប់គ្រង និងទិដ្ឋាកានាំចេញ | ១០៦% | +១% |

| មុខចំណូល | អនុវត្តច្បាប់ថវិកា | %Δធៀបនឹងឆ្នាំ២០១២ |
|---|---|---|
| **ចំណូលមិនមែនសារពើពន្ធ** * | ៨៣% | -១៥% |
| ✓នេសាទ | ៥៣% | -៦១% |
| ✓ រុក្ខាប្រមាញ់ | ២១១% | +៥៨% |
| ✓សម្បទានរ៉ែ | ១០៩% | -៨៩% |
| ✓អាកាសចរណ៍ស៊ីវិល | ១០៨% | -៣% |
| ✓ ផលទុនទេសចរណ៍ | ៨០% | -៤% |
| ✓ប្រៃសណីយ៍ និងទូរគមនាគមន៍ | ១៦៧% | +៣៥% |
| ✓អាករស្ពានទូត | ១២៥% | -១% |
| ✓ ត្រួតពិនិត្យគុណភាពផលិតផល | ១៥៦% | +៦% |
| ✓ ជួលរោងចក្រ សហគ្រាសសម្ភារៈ | ៦៦% | -១៥% |
| ✓ ឯកជនភាវូបនីយកម្ម | ០% | -១០០% |
| ✓ ការលក់អចលនកម្ម | ៧២៦១៣% | +៨១% |

* តួលេខរតនាគាជាតិ ** តួលេខអគ្គនាយកដ្ឋានគយ និងរដ្ឋាករ ***តួលេខអគ្គនាយកដ្ឋានពន្ធដារ

- ចំណាយថវិកាជាតិក្នុងឆ្នាំ២០១៣ អនុវត្តបាន ៦៤៧០ ពាន់លានរៀល ស្មើនឹង ៦០% នៃច្បាប់ថវិកា ក្នុងនោះៈ ចំណាយចរន្ត ៥១៧៧ពាន់លានរៀល ស្មើនឹង ៨៣% នៃច្បាប់ថវិកា និងចំណាយមូលធន ១២៩៣ពាន់លានរៀល។
- បើធៀបនឹងឆ្នាំមុន ចំណាយថវិកាជាតិថយចុះ ៥% ក្នុងនោះចំណាយចរន្តថយចុះ ១១% ប៉ុន្តែចំណាយមូលធនកើនឡើង ៣៣%។
- ជាលទ្ធផល ថវិកាជាតិនាឆ្នាំ២០១៣ មានអតិរេកចំនួន ១៥៩៤ពាន់លានរៀល។ ប៉ុន្តែគួរកត់សម្គាល់ថា តារាងទិន្នន័យថវិការជាតិបង្ហាញតែតួលេខចំណាយមូលធនដែលឆ្លងកាត់រតនាគារជាតិប៉ុណ្ណោះ។

### ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

- សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៣ មានសូចនាកររូបិយវត្ថុដូចខាងក្រោមៈ
  ⇨ រូបិយវត្ថុ *M2* មានចំនួន ៣២៧៦៨ ពាន់លានរៀល កើនឡើង១៥% ធៀបនឹងឆ្នាំ២០១២។

**សមាសធាតុរូបិយវត្ថុ ឆ្នាំ ២០១៣** ( % នៃរូបិយវត្ថុទូទៅ *M2* )




**សមាសធាតុរូបិយវត្ថុ ឆ្នាំ ២០១២**




⇨សមាសធាតុរូបិយវត្ថុមិនសូវមានការប្រែប្រួលគួរឲ្យចាប់អារម្មណ៍ទេ។ រូបិយវត្ថុក្រៅធនាគារកើនឡើងពី ១៣% នៃ M2 ក្នុងឆ្នាំ២០១២ មក ១៤% នៃM2 ក្នុងឆ្នាំ២០១៣។ ឯប្រាក់បញ្ញើជារូបិយបណ្ណបរទេស ថយចុះពី ៨៣% មក ៨២% នៃM2 ។

⇨ តារាងខាងក្រោមបង្ហាញកំណើនសូចនាកររូបិយវត្ថុធៀបនឹងឆ្នាំមុន ( ២០០៩-២០១៣ )

| | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ |
|---|---|---|---|---|---|
| *M2* | +៣៧% | +២០% | +២១% | +២១% | +១៥% |
| *M1* | +៣០% | +៣% | +២៣% | +២% | +២១% |
| រូបិយវត្ថុក្រៅធនាគារ | +៣១% | +៣% | +២២% | 0 | +១៩% |
| ប្រាក់បញ្ញើចរន្ត | +១៣% | +៣% | +៥១% | +៥៧% | +៤៦% |
| រូបិយវត្ថុផ្សេងៗ | +៣៨% | +២៤% | +២១% | +២៥% | +១៤% |
| ប្រាក់បញ្ញើមានកាលកំណត់និងសន្សំ | +៩៤% | +១៤% | +៣៦% | +៤០% | +២១% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +៣៧% | +២៤% | +២១% | +២៤% | +១៣% |

⇨ ក្នុងឆ្នាំ២០១៣ រូបិយវត្ថុទូទៅ*M2* មានការកើនឡើងទាបជាងឆ្នាំមុនៗ ។ *M2* មានចំនួនប្រហែល ៥៣% នៃផសស ប៉ុន្តែ**សមមាត្រ** *M1* ក្នុងផសស មានត្រឹមតែ ៧,៩% ប៉ុណ្ណោះ។ ក្នុងអំឡុងពេលបីឆ្នាំចុងក្រោយ ប្រាក់បញ្ញើចរន្តមានការកើនឡើងគួរឲ្យកត់សម្គាល់។

- ទុនបំរុងជារូបិយប័ណ្ណបរទេសសុទ្ធ មានចំនួន ៣៤៥៩ លានដុល្លារ កើនឡើង ៣% ធៀបនឹងឆ្នាំ២០១២។
- ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅ**ធនាគារជាតិនៃកម្ពុជា** មានចំនួន ១០៤៨០ ពាន់លានរៀល កើនឡើង ១១% បើធៀបនឹងឆ្នាំមុន។
- ឥណទានផ្តល់ដោយធនាគារពាណិជ្ជមានចំនួន ២៩៨៣៥ពាន់លានរៀល កើនឡើង ២៦% ធៀបនឹងឆ្នាំមុន។
- ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុមានចំនួន ៥២៦២ពាន់លានរៀល កើនឡើង ៤៩% ។

➢ អត្រាការប្រាក់ប្រចាំឆ្នាំ៖

| *ប្រភេទអត្រាការប្រាក់* | *អត្រាឆ្នាំ* ២០១៣ | *អត្រាឆ្នាំ* ២០១២ | %Δ (២០១៣/២០១២) |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៥,៨% | ៥,៩% | -១% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១៥,៧២% | ១១,៧៩% | +៣៣% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៤,២៧% | ៤,៤៤% | -៤% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ១១,៣៥% | ១១,៦១% | -២% |
| កម្ចីជារៀលនៅហត្ថកសិករ | ៣១,២% | ៣៦,០ | -១៣% |
| កម្ចីជារៀលនៅអម្រឹត | ៣២,១% | ២៨,២ | +១៤% |
| កម្ចីជារៀលនៅស្ថាបនា | ៣១,២% | ៣៣,០ | -៥% |
| កម្ចីជារៀលនៅប្រាសាក់ | ៣១,៨% | ៣១,៨% | 0 |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងវប្បធម៌

➢ ***កសិកម្ម៖***

⇨ ក្នុងឆ្នាំ២០១៣ ផលិតផលស្រូវមានបរិមាណ ៩៣៤០ពាន់តោន កើនឡើង0.៤% បើធៀបនឹងឆ្នាំ២០១២។ ក្នុងរយៈពេល៥ឆ្នាំចុងក្រោយ (២០០៨-២០១៣) ផលិតផលស្រូវកើនជាមធ្យម ៧%ក្នុងមួយឆ្នាំ ។







⇨ ក្នុងឆ្នាំ ២០១៣ ការដាំស្រូវទាំងពីររដូវបានធ្វើលើផ្ទៃដីចំនួន ២៩៥៨ពាន់ហិកតា តិចជាងឆ្នាំ២០១២ ចំនួន ១៣ពាន់ហិកតា។

⇨ ក្នុងឆ្នាំ២០១៣ ផលិតផលកៅស៊ូមានចំនួន ៨៥,៣ពាន់តោន កើនឡើង ៣២,២% ។ ផ្ទៃដីចៀរជ័រមានចំនួន ៧៨,៥ ពាន់ហិកតា និងផ្ទៃដីដាំដុះសរុបមាន ៣២៨,៨ ពាន់ហិតា។

⇨ ផលិតកម្មនេសាទឆ្នាំ២០១៣ មានចំនួន ៧០៩,៥ ពាន់តោនកើនឡើង ៧%ធៀបនឹងឆ្នាំ២០១២។

➢ ***ឧស្សាហកម្ម៖***

⇨ថាមពលអគ្គិសនីផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៣៧៦៥ GWh កើនឡើង ១៥% ។ ក្នុងនោះ វារីអគ្គិសនីមានចំនួន១០៨០,៩ GWh កើនឡើង ១១១%។

⇨ផលិតកម្មវាយនភណ្ឌនិងស្បែកជើងសម្រេចបាន៥២១៨ លានដុល្លារ កើនឡើង១៦%។

⇨ទឹកស្អាតផ្គត់ផ្គង់ដោយរដ្ឋាករទឹកមានចំនួន ១៧៤,៤លានម៣កើនឡើង ១១% ។

⇨ **ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស នៅក្រសួងឧស្សាហកម្ម៖**

| *ប្រភេទ* | *ចំនួន : ២០១៣* | *ចំនួន: ២០១២* | %∆ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ១១២០ | ៩០៨ | +២៣% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ២១១ | ២០២ | +៤% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២៤៦ | ២១៤ | +១៥% |
| ឧស្សាហកម្មធនតូច និងសិប្បកម្ម (បន្ត) | ១៥១ | ១៥៤ | -២% |

⇨**សំណង់ (ការអនុញ្ញាត)៖**

▪ ការអនុញ្ញាតឲ្យសាងសង់ឆ្នាំ ២០១៣ មានទឹកប្រាក់ស្មើនឹង ២៧៧៣លានដុល្លារ កើនឡើង ៣១% ធៀបនឹងឆ្នាំ ២០១២។

| *ប្រភេទសំណង់* | ពាន់ម$^{២}$ :២០១៣ | ពាន់ម$^{២}$ :២០១២ | % ∆ |
|---|---|---|---|
| លំនៅឋាន | ២០៧៥ | ២៦៨២ | -២៣% |
| ឧស្សាហកម្ម | ១៤៨០ | ២០០៦ | -២៦% |
| ពាណិជ្ជកម្ម | ៣២០៣ | ១១៦៦ | +១៧៥% |
| ទេសចរណ៍ | ២១០ | ៣៨៦ | -៤៦% |
| ... | ... | ... | ... |
| អនុញ្ញាតសរុប | ៧៥៩៦ | ៦៥២៨ | +១៦% |

▪ ក្នុងការអនុញ្ញាតឆ្នាំ២០១៣នេះ សំណង់ដែលពេញនិយមមាន លំនៅឋាន (២៧% នៃផ្ទៃក្រឡាសរុប) ឧស្សាហកម្ម (១៩% នៃផ្ទៃក្រឡាសរុប) និងពាណិជ្ជកម្ម (៤២% នៃផ្ទៃក្រឡាសរុប)។

▪**ការងារ៖**

| *ប្រភេទ* | ២០១៣ (នាក់) | ២០១២ (នាក់) | %∆ |
|---|---|---|---|
| ការដាក់ពាក្យរកការងារទៅក្រៅប្រទេស | ១៦២៣៤ | ៣០៦២៧ | –៤៧% |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ៣៣៨២៤ | ៥២៩៨៤ | -៣៦% |
| អ្នកទទួលបានការងារក្នុងប្រទេស | ២០០៤៤ | ២៦២៨២ | -២៤% |
| អ្នកទទួលបានការងារក្រៅប្រទេស | ១៣៧៨០ | ២៦៧០២ | -៤៨% |

▪ **វិនិយោគ** : គម្រោងវិនិយោគអនុញ្ញាតដោយ គ.វ.ក./ក.អ.ក. ក្នុងឆ្នាំ២០១៣ (ថ្មី និងពង្រីក) មានចំនួន ២២៥ គម្រោង។ ជាទុនវិនិយោគមានទឹកប្រាក់ **៤៩៦២**លានដុល្លារ និងអាចផ្តល់ការងារបាន ២៨១ពាន់នាក់។

| *ប្រភេទ* | *២០១៣* | *២០១២* | %∆ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៤៩៦២ | ២៩៦៦ | +២៨% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ១១២៩ | ៥៥៧ | +១០៣% |
| វិស័យឧស្សាហកម្ម | ១១០៧ | ១៤៨៩ | -២៦% |
| វិស័យទេសចរណ៍ | ១០៦ | ៦៩២ | -៨៥% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ២៦២១ | ២២៨ | +១០៥១% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ២២៥ | ២១៨ | +៣% |
| **ចំនួនពលករ (ពាន់នាក់)** | ២៨១ | ៣៣៤ | -១៦% |

▪ *សេវាកម្មនិងទេសចរណ៍៖*

➢ការចុះបញ្ជីនិងលុបចេញពីបញ្ជី

| *ប្រភេទ* | ២០១៣ (*ចំនួន*) | ២០១២(ចំនួន) | %∆ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ២៩៨៦ | ៣៣៨៦ | -១២% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ២៤ | ៥៥ | -៥៦% |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | - | ២៤៧៨ | - |

➢**ទំនិញឆ្លងកាត់កំពង់ផែ** (សរុប៦កំពង់ផែ)មានចំនួន ៦៤៥៥ពាន់តោនកើនឡើង២១%។ ក្នុងនោះ៖

| *ប្រភេទ* | ២០១៣ (ពាន់តោន) | ២០១២ (ពាន់តោន) | %∆ |
|---|---|---|---|
| កំពង់ផែភ្នំពេញ | ១៤៨៥ | ១៦២៨ | -៩% |
| កំពង់ផែកំពង់សោម | ៣០៧៨ | ២៥៧២ | +២០% |
| កំពង់ផែស្រែអំបិល និងកោះកុង | ១០៧២ | ៤៩៥ | +១១៧% |
| កំពង់ផែឧកញ៉ាម៉ុង | ៨១៤ | ៦៣៤ | +២៨% |

➢**អ្នកដំណើរតាមផ្លូវអាកាស និងទេសចរណ៍**

| *ប្រភេទ* | ២០១៣ (ពាន់នាក់) | ២០១២ (ពាន់នាក់) | %∆ |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ១០៨ | ១០១ | +៧% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ២១៤ | ១៧២ | +២៥% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៤៦០៦ | ៣៩៩២ | +១៥% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ៨៧២ | ៧៩២ | +១០% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ៤២១០ | ៣៥៨៤ | +១៧% |
| ✓តាមផ្លូវអាកាស | ២១៩៣ | ១៧២២ | +១៧% |
| ✓ តាមផ្លូវគោក និងទឹក | ២២០៥ | ១៨៦២ | +១៨% |

## ៥)ស្ថានភាពពាណិជ្ជកម្ម

▪ យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០១៣ មានចំនួន៣៦៥១៥ពាន់លានរៀលកើនឡើង ២០% បើធៀបនឹងឆ្នាំ ២០១២។ ក្នុងនោះ:

| មានការថយចុះ | មានការកើនឡើង | |
|---|---|---|
| ប្រេងខ្មៅ -២២% | ប្រេងសាំង +១% | ផ្លែឈើនិងបន្លែ +៨% |
| ដែកសំណង់ -២៦% | ប្រេងម៉ាស៊ូត +២% | ជីនិងថ្នាំកសិកម្ម +២១% |
| អង្ករ -១៧% | ឧស្ម័ន +១៥% | ស្ករស +៤០% |
| បារី -៤% | អគ្គិសនីនាំចូល +៨% | ភេសជ្ជៈ +៦៤% |
| | ស៊ីម៉ង់ +៩% | ប្រេងឆា +៧៩% |
| | រថយន្តសរុប (ជាសាច់ប្រាក់) +១% | ប៊ីចេង +១០៧% |
| | ត្រាក់ទ័រនិងគោយន្ត +៦៦% | នាំចូលក្នុងក្របខ័ណ្ឌច្បាប់វិនិយោគ +៣០% |
| | គ្រឿងអេឡិចត្រូនិច +៣% | |
| | ម៉ូតូ +១% | |

- **ការនាំចេញ**ឆ្នាំ២០១៣ មានចំនួន២៨១១១ពាន់លានរៀលកើនឡើង២៥%ធៀបនឹងឆ្នាំ២០១២។ក្នុងនោះ៖

| ទំនិញ | %Δធៀបនឹង -២០១២ | ទំនិញ | %Δធៀបនឹង -២០១២ |
|---|---|---|---|
| ផលិតផលឈើកែច្នៃ | +១៥៨% | ផលិតផលនេសាទ | -៥៣% |
| វាយនភណ្ឌនិងស្បែកជើង | +១៧% | កៅស៊ូ | +៣៦% |
| អង្ករ | +៩០% | | |

- ក្នុងឆ្នាំ២០១៣ ជញ្ជីងពាណិជ្ជកម្មមានឱនភាពចំនួន *៨៤០៤ពាន់លានរៀល ស្មើនឹង* ២១០១លានដុល្លារ ។

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងឆ្នាំ២០១៣នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៃព្រះរាជាណាចក្រកម្ពុជា បង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖

| សូចនាករ | បម្រែបម្រួលធៀបនឹងឆ្នាំ ២០១២ | ផ្សេងៗ |
|---|---|---|
| **១. អតិផរណា** | +៣% | **អតិផរណាមានកម្រិតទាប ប៉ុន្តែអត្រានេះមិនមានស្ថិរភាព** |
| ២. ថ្លៃសាច់គោ | +១២% | បញ្ហាតម្រូវការ និងការផ្គត់ផ្គង់ |
| ៣. ថ្លៃបន្លែ | +៧% | បញ្ហាតម្រូវការ និងការផ្គត់ផ្គង់ |
| **៤. ចំណូលថវិកាជាតិ** | +២% | **អនុវត្តបានតែ៦៨% នៃច្បាប់ថវិកា** |
| ៥. ចំណូលមិនមែនសារពើពន្ធ | -១៥% | — |
| **៦. ចំណាយថវិកាជាតិ** | -៥% | **អនុវត្តបានតែ៦០% នៃច្បាប់ថវិកា** |
| ៧. ក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្មនៅក្រ.ពាណិជ្ជកម្ម | -១២% | — |
| **៨. រូបិយវត្ថុទូទៅ M2** | +១៥% | **កំណើន M2 មានការថយចុះពីរង្វង់ ២៥-៣០% មកនៅត្រឹម ១៥% ក្នុងឆ្នាំ២០១៣** |

## ៧) ស្មារតីអង្គប្រជុំ និងការសន្និដ្ឋាន

***អង្គប្រជុំបានពិភាក្សាបញ្ហាសំខាន់ គួរឲ្យចាប់អារម្មណ៍ដូចខាងក្រោម៖***

១) ជារួម អត្រាអតិផរណាឆ្នាំ ២០១៣ មានកម្រិតទាប ប៉ុន្តែមុខទំនិញសំខាន់ៗមួយចំនួនមានការឡើងថ្លៃ ដូចជា ឧស្ម័ន ជីកសិកម្ម និងផលិតផលនាំចូលដទៃទៀត។

២) សមាហរណកម្មនៃសហគមន៍សេដ្ឋកិច្ចអាស៊ាន ក្នុងឆ្នាំ២០១៥ខាងមុខ ធ្វើឲ្យកម្ពុជាប្រឈមនឹងបញ្ហាចម្បងគឺ ការថយចុះនៃចំណូលពន្ធគយស្ទើរតែទាំងស្រុង ដូច្នេះវិធានការដែលគួរប្រកាន់យកគឺការបង្កើនចំណូលពន្ធដារ ពន្ធអាករ និងចំណូលផ្សេងៗ ដើម្បីឆ្លើយតបបានចំពោះការធ្លាក់ចុះនៃពន្ធគយនេះ។

៣) សំណង់អនុញ្ញាតមានការកើនឡើងគួរឲ្យចាប់អារម្មណ៍ គិតជាផ្ទៃក្រឡា កើនឡើង ១៦% និងជាសាច់ប្រាក់កើនឡើង ៣១% ។ តួលេខនេះឆ្លុះបញ្ចាំងអំពីកំណើននៃសំណង់ខ្នាតធំ។

៤) តួលេខវិនិយោគឆ្នាំ២០១៣ បង្ហាញថា មួយភាគធំហូរទៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ ស្មើនឹង ៥៣% នៃសាច់ប្រាក់ អនុញ្ញាតសរុប ក្រៅពីនោះ ទៅក្នុងវិស័យកសិកម្ម និងកសិឧស្សាហកម្ម ២៣% និងទៅក្នុងឧស្សាហកម្ម ២២%។

# សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៤

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | ០៧/០១/១៤<br>ម៉ោង ០៧:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីមីទ្ទីងអបអរសាទរខួបលើកទី៣៥ ទិវាជ័យជំនះ ៧មករា នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ២ | ០៨/០១/១៤<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងផែនការយុទ្ធសាស្រ្តជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅ ជនបទឆ្នាំ២០១៤-២០២៥។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាម ការជក់ និងការបង្អួយផ្សែងផលិតផលថ្នាំជក់នៅកន្លែង ធ្វើការ និងកន្លែងសាធារណៈ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌ឱសថការី។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៣ | ១០/០១/១៤<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងផែនការយុទ្ធសាស្រ្តជាតិស្តីពីការផ្គត់ផ្គង់ទឹកស្អាត និងការលើកកម្ពស់អនាម័យនៅ ជនបទឆ្នាំ២០១៤-២០២៥។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីវិធានការហាម ការជក់ និងការបង្អួយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ និងកន្លែងសាធារណៈ។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌ឱសថការី។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ៤ | ១៣/០១/១៤<br>ម៉ោង ០៨:០០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការ មន្ទីរពេទ្យជោរៃ-ភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម **ង្វៀន តាន់យុង** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសង្កាត់និរោធ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ |
| ៥ | ១៥/០១/១៤<br>ម៉ោង ០៩:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក Herve Baj នាយកប្រតិបត្តិក្រុមហ៊ុន ហ្គេនធីង ធីមវើក ខនស្រ្តាក់សិន នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៦ | ១៥/០១/១៤<br>ម៉ោង ១០:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **សឿន សម្បត្តិ** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |

## សកម្មភាពផ្សេងៗរបស់ឯកឧត្តម យឹម ឈុលឡា ទេសរដ្ឋមន្ត្រី
## ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌
## ប្រចាំខែមករា ឆ្នាំ២០១៤ (ត)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៧ | ១៦/០១/១៤<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងអនុក្រឹត្យស្តីពីអាហារូបករណ៍ និងរបបឧបត្ថម្ភជីវភាពអន្តេវាសិក សម្រាប់សិស្ស និស្សិត សិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ។<br>២-បញ្ហាផ្សេងៗ៖<br>២.១-សេចក្តីព្រាងកិច្ចព្រមព្រៀងស្តីពីបុព្វសិទ្ធិ និងអភ័យឯកសិទ្ធិរបស់សមាគមន៍ប្រជាជាតិ អាស៊ីអាគ្នេយ៍ និងពិធីសារ នៃធម្មនុញ្ញអាស៊ានស្តីពីយន្តការដោះស្រាយជម្លោះ។<br>២.២- សេចក្តីព្រាងកិច្ចព្រមព្រៀង បង្កើតមជ្ឈមណ្ឌលជីវៈចម្រុះអាស៊ាន (ACB) និងអនុញ្ញាត គោលការណ៍លើការបង់វិភាគទានសម្រាប់ដំណើរការមជ្ឈមណ្ឌល។<br>ដើម្បីត្រៀមប្រជុំត្រួតពិនិត្យចុងក្រោយ ជាមួយឯកឧត្តម បណ្ឌិតសភាចារ្យ សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៨ | ២០/០១/១៤<br>ម៉ោង ០៩:០០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំគណៈកម្មការដោះស្រាយពាក្យបណ្តឹងតវ៉ា និងត្រៀមរៀបចំជួបប្រជុំជាមួយប្រជាពលរដ្ឋរងផលប៉ះពាល់នៅជាប់របងជុំវិញបរិវេណអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៩ | ២២/០១/១៤<br>ម៉ោង ១៥:៣០នាទី | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីផ្លូវថ្នល់។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌គិលានុបដ្ឋាក។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង។<br>៤-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១០ | ២៣/០១/១៤<br>ម៉ោង ១៥:៣០នាទី | ចូលរួមជាអធិបតី ក្នុងកិច្ចប្រជុំគណៈកម្មការព្រលានយន្តហោះ នៅព្រលានយន្តហោះអន្តរជាតិភ្នំពេញ។ |
| ១១ | ២៤/០១/១៤<br>ម៉ោង ០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ស្តីពីផ្លូវថ្នល់។<br>២-សេចក្តីព្រាងអនុក្រឹត្យស្តីពីក្រមសីលធម៌គិលានុបដ្ឋាក។<br>៣-សេចក្តីព្រាងអនុក្រឹត្យស្តីពីការបង្កើតតំបន់ព្រៃការពារសម្រាប់អភិរក្សធនធានសេនេទិចរុក្ខជាតិ និងសត្វព្រៃសៀមប៉ាង ខេត្តស្ទឹងត្រែង។<br>៤-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

## សកម្មភាពដទៃទៀតរបស់ឯកឧត្តម យឹម ណុលឡា ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមករា ឆ្នាំ២០១៤ (តចប់)

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១២ | ២៤/០១/១៤ ម៉ោង ១៦:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក **Lee Hyung Jong** អំពីគម្រោងវិនិយោគសាងសង់អគារសារមន្ទីរសព្វទស្សន៍ (Grand Panorama Museum) នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការ គណៈរដ្ឋមន្ត្រី។ |
| ១៣ | ២៨/០១/១៤ ម៉ោង ០៩:០០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយលោក **Herve Baj** នាយកប្រតិបត្តិក្រុមហ៊ុន ហ្គេនធីងធីមរើក ខនស្រ្តាក់សិន នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៤ | ២៨/០១/១៤ ម៉ោង ១០:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តម **ឃុយហាន ថាវរិទ្ធ** ឯកឧត្តម **អ៊ុំ កុសល** និងឯកឧត្តម **សួង ជីវគុណា** នៅបន្ទប់ ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៥ | ២៨/០១/១៤ ម៉ោង ១៥:០០នាទី | ចូលរួមស្តាប់បទបាឋកថា ដែលថ្លែងដោយ ឯកឧត្តម បណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ស្តីអំពីការបកស្រាយបំភ្លឺចំពោះរបាយការណ៍រួមរបស់សម្ព័ន្ធ កំណែទម្រង់ការបោះឆ្នោតស្តីពីការរៀបចំការបោះឆ្នោតឆ្នាំ២០១៣ នៅកម្ពុជា នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១៦ | ២៩/០១/១៤ ម៉ោង ០៧:៣០នាទី | ចូលរួមក្នុងអង្គប្រជុំផ្សព្វផ្សាយសេចក្តីសម្រេចរាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការនាយករដ្ឋមន្ត្រី។ |

# សិក្ខាសាលាស្តីពីការតាមដានការអនុវត្តគម្រោង វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត នៅខេត្តរតនៈគិរី

កាលពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៤ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ដោយមានការគាំទ្រពីធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានរៀបចំសិក្ខាសាលាស្តីពីការតាមដានការអនុវត្តគម្រោងវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) នៅខេត្តរតនៈគិរី ក្រោមអធិបតីភាព ឯកឧត្តម យឹម ណុលសន អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជានាយកគម្រោង RIA។

សិក្ខាសាលានេះមានការអញ្ជើញចូលរួមពីសំណាក់ថ្នាក់ដឹកនាំនិងមន្ត្រីគម្រោងRIA រួមទាំងក្រសួងអនុវត្តគម្រោងទាំង៧ គឺក្រសួងពាណិជ្ជកម្ម ក្រសួងបរិស្ថាន ក្រសួងរ៉ែនិងថាមពល ក្រសួងទេសចរណ៍ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា និងមន្ត្រីគម្រោងRIA ទាំងអស់។




ក្រសួងអនុវត្តគម្រោងចំនួន៣ បានធ្វើបទបង្ហាញពីការអនុវត្តការវាយតម្លៃបឋមលើសំណើបញ្ញត្តិកម្ម ដោយប្រើប្រាស់វិធីសាស្ត្រ RIA ដោយមិនមានជំនួយពីទីប្រឹក្សាអន្តរជាតិ ចំណែកឯក្រសួងពាណិជ្ជកម្មមានបានធ្វើបទបង្ហាញពីដំណើរការនៃការអនុវត្តការវាយតម្លៃពេញលេញ(RIS)លើសេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង។

ក្រសួងចំនួន៣ ដែលទើបចូលរួមអនុវត្តគម្រោង គឺក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងអប់រំ យុវជន និងកីឡា និងមន្ត្រីគម្រោងRIA មានការចាប់អារម្មណ៍ចំពោះវិធីសាស្ត្រ RIA ដោយបានលើកជាសំណួរនិងអធិប្បាយយ៉ាងផុលផុស។

សិក្ខាសាលាក៏បានដាក់ឲ្យពិភាក្សាសេចក្តីព្រាងអនុក្រឹត្យស្តីពីការអនុវត្តការវាយតម្លៃលើលិខិតបទដ្ឋានគតិយុត្ត ដែលនឹងស្នើសុំសេចក្តីសម្រេចពីរាជរដ្ឋាភិបាលនាពេលខាងមុខ។



ជាទីបញ្ចប់ ឯ.ឧ យឹម ណុលសន អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ និងជានាយកគម្រោង RIA បានធ្វើការវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងអនុវត្តគម្រោងកន្លងមក ហើយបានធ្វើការណែនាំដល់ក្រសួងចំនួន៣ ដែលទើបចូលរួមក្នុងគម្រោង ត្រូវខិតខំអនុវត្តគម្រោងឲ្យទទួលបានលទ្ធផលល្អ។



# ព្រឹត្តិបត្រព័ត៌មាន


| | | |
|---|---|---|
| នាយកគ្រប់គ្រងទូទៅ: | ឯកឧត្តម គីម សយសាម៉ាឡែន | អនុប្រធាន ក.ស.វ. |
| និពន្ធនាយក: | ឯកឧត្តម ង៉ាន់ ភិរុណ | អគ្គលេខាធិការ ក.ស.វ. |
| និពន្ធអគ្គបទ: | ឯកឧត្តម អេង វឌ្ឍមុនី | អគ្គលេខាធិការរង ក.ស.វ. |
| វិភាគស្ថានភាពសេដ្ឋកិច្ច: | ឯកឧត្តម ម៉ម សារិទ្ធ | សមាជិកបម្រុង ក.ស.វ. |
| ទំនាក់ទំនងនិងបោះពុម្ពផ្សាយ: | លោក ម៉ក់ ធារ៉ា | ប្រធានផ្នែក ក.ស.វ. |
| បច្ចេកទេសកុំព្យូទ័រនិងសម្របសម្រួល: | លោក សយ វាស្នា | អនុប្រធានផ្នែក ក.ស.វ. |
| យកព័ត៌មាននិងថតរូប: | លោក មុត កក្កដា | មន្ត្រី ក.ស.វ. |




## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in